ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ១៣៤ . អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការទទួលស្គាល់វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ០១ អនក្រ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុបណ្តាលវិជ្ជាជីវៈ

**មាត្រា ១.-**

ទទួលស្គាល់វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ ដែលមានអក្សរកាត់ " វ.ហ.គ. " និងជាភាសាអង់គ្លេសថា Institute of Finance and Accounting ដែលមានអក្សរកាត់ " I.F.A "។ វិទ្យាស្ថាននេះ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានទីតាំងស្ថិតនៅអគារលេខ១៥៨ A ផ្លូវលេខ ២៧១ សង្កាត់បឹងសាឡាង ខណ្ឌទួលគោក រាជធានីភ្នំពេញ។

**មាត្រា ២.-**

វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ មានភារកិច្ចធ្វើការបណ្តុះបណ្តាល ៖

- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ សិក្សារយៈពេលយ៉ាងតិច០៤ឆ្នាំ ត្រូវនឹង១២០ក្រេឌីតឡើងទៅ។

**មាត្រា ៣.-**

វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ មានរចនាសម្ព័ន្ធដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល
- ការិយាល័យសិក្សា
- ការិយាល័យផែនការ និងហិរញ្ញវត្ថុ
- ការិយាល័យស្រាវជ្រាវ និងអភិវឌ្ឍន៍
- ការិយាល័យទំនាក់ទំនង នឹងផ្សព្វផ្សាយ
- មហាវិទ្យាល័យសេដ្ឋកិច្ច និងពាណិជ្ជកម្ម
- មហាវិទ្យាល័យគ្រប់គ្រង និងទេសចរណ៍
- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសាបរទេស
- មហាវិទ្យាល័យនីតិសាស្ត្រ
- មហាវិទ្យាល័យវិទ្យាសាស្ត្រកុំព្យូទ័រ
- មហាវិទ្យាល័យកសិកម្ម និងអភិវឌ្ឍន៍ជនបទ
- មហាវិទ្យាល័យវិស្វកម្ម និងសំណង់

នៅថ្ងៃអនាគតវិទ្យាស្ថាននេះ អាចបើកសាខា ឬមហាវិទ្យាល័យ ឬឯកទេសដទៃទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៤.-**

លក្ខខណ្ឌទទួលនិស្សិត ឲ្យចូលរៀន ៖

- ថ្នាក់វិស្វករ ឬបរិញ្ញាបត្រ បេក្ខជនមានសញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស ឬឯកទេស ឬបរិញ្ញាបត្ររង ឬ សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រដែលមានតម្លៃស្មើ។

[illegible]
កំណត់អំពីការជ្រើសរើសការបណ្តុះបណ្តាល ការប្រឡងបញ្ចប់ការសិក្សារបស់និស្សិត។

**មាត្រា ៥.-**

វិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ មាននាយកមួយរូប និងមាននាយករងមួយចំនួន ជាជំនួយការតាមការចាំបាច់។ វិទ្យាស្ថានត្រូវធ្វើរបាយការណ៍រាល់សកម្មភាពសិក្សា ជូននាយកដ្ឋានគ្រប់គ្រងកិច្ចការអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាល វិជ្ជាជីវៈ ឲ្យបានទៀងទាត់តាមការកំណត់។

**មាត្រា ៦.-**

និស្សិតដែលបានរៀនចប់កម្មវិធីសិក្សារបស់វិទ្យាស្ថាននេះ និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលបានសញ្ញាបត្រតាមឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ផ្តល់ឲ្យដោយវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ នឹងត្រូវបានទទួលស្គាល់ពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងករណីវិទ្យាស្ថាននេះបានបំពេញ និងអនុវត្តតាមគោលការណ៍របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា ៧.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងនាយកវិទ្យាស្ថានហិរញ្ញវត្ថុ និងគណនេយ្យ ត្រូវទទួលបន្ទុក អនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ សីហា ឆ្នាំ២០១២

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

កន្លែងទទួល៖
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- គណៈកម្មាធិការជាតិបណ្តុះបណ្តាល
- គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា ៧
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ